# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមព្រហ្មទណ្ឌ**

-លេខ: ២៩២ "ក្រ.វ"

-ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៨០

ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣

-សើុបសួរលេខ ៣២៥០

ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

-ជំនុំជម្រះលេខ ២៥៨

ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤

## តាមនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ វេលាម៉ោង ០២ និង ០០ នាទីរសៀល នៅសាលសវនាការទី២ ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា

-លោក [redacted] ចៅក្រុមប្រឹក្សា

-លោក [redacted] ចៅក្រុមប្រឹក្សា

### តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៨០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ ឈ្មោះ [redacted] សុធាវិន ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ ជាងម៉ូតូ ទីកន្លែងកំណើត[redacted] ទីលំនៅមុនពេលឃាត់ខ្លួននៅផ្លូវបេតុង ភូមិដំណាក់ សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ[redacted] សាហុន "រស់" ម្ដាយឈ្មោះ [redacted] ចន្ទី "រស់" ជាអនីតិជន ប្រវត្តិផ្ដន្ទាទោសដោយតុលាការ-គ្មាន ។

-តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៥៤៣ "ល" ដ.ឃ.ង ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ។ (PJ)

ជាប់ចោទពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីអំឡុងខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែល មានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-មេធាវី [redacted] ជាមេធាវីចាត់តាំងការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted] សូត្រ ភេទស្រី អាយុ ៦៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្លូវលំ ភូមិត្រពាំងព្រៃ ឃុំបាក់អន្លង់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

-ជនរងគ្រោះឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ ១៣ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះគ្មានលេខ ផ្លូវលំ ភូមិត្រពាំងព្រៃ ឃុំបាក់អន្លង់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

-មេធាវី [redacted] ជាមេធាវីចាត់តាំងការពារសិទ្ធិឱ្យជនរងគ្រោះ ។

### អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងខែឧសភា ឆ្នាំ២០២៣ នៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ មានករណីអំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តដោយជនសង្ស័យឈ្មោះ [redacted]



Scanned with CamScanner

សុធាវិន បានរាប់អានស្រឡាញ់គ្នាជាមួយសង្សារជាជនរងគ្រោះឈ្មោះ [redacted] ម៉ារី ភេទស្រី អាយុ ១២ឆ្នាំ ដោយនៅថ្ងៃកើតហេតុ ជនសង្ស័យបានជិះម៉ូតូឌុបជនរងគ្រោះដើរលេង នៅពេលយប់បន្តិចជនសង្ស័យក៏បានសុំជនរងគ្រោះទៅរួមភេទជាមួយ ដោយមានចិត្តស្រឡាញ់ ជនរងគ្រោះក៏បានយល់ព្រមរួមភេទជាមួយជនសង្ស័យបានសម្រេច ។ ហើយនៅយប់មួយក្នុងខែឧសភា ឆ្នាំ២០២៣ នេះដដែល ជនសង្ស័យក៏បានសុំជនរងគ្រោះរួមភេទជាមួយម្តងទៀត ជនរងគ្រោះក៏បានយល់ព្រម និងបានរួមភេទជាមួយគ្នាបានសម្រេចជាលើកទី២ ។ លុះបីថ្ងៃក្រោយជនសង្ស័យ និងជនរងគ្រោះក៏បានយល់ព្រមគ្នារួមភេទជាលើកទី៣ បានសម្រេចម្តងទៀត ហើយនៅខែកក្កដា ឆ្នាំ២០២៣ ជនរងគ្រោះក៏ចេញទៅរស់នៅខេត្តឧត្តរមានជ័យ ជាមួយគ្រួសារ បន្ទាប់មកជនរងគ្រោះក៏បានប្រាប់ពីដំណើររឿងដែលធ្លាប់បានរួមភេទជាមួយជនសង្ស័យសរុបចំនួន ៣លើក នោះប្រាប់ទៅជីដូន ភ្លាមនោះជីដូនរបស់ជនរងគ្រោះក៏ខឹងសម្បារនឹងជនសង្ស័យ លុះដល់ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ជីដូនរបស់ជនរងគ្រោះក៏បាននាំជនរងគ្រោះចេញពីខេត្តឧត្តរមានជ័យ មកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលគោកឃ្លាង ដើម្បីចាត់ការបន្តតាមនីតិវិធីតែម្តង ។

-បានឃើញ៖ របាយការណ៍សំយោគលេខ ១៨០/២៣ របក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៣២៤០ អ.យ.ផ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ៖ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៨៣៥ អ.យ.ផ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ៖ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦២២៦ “ល” ដ.ដ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

## នារពេលសខនាការ

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] ម៉ារី បានឆ្លើយថា៖ នៅខែវិច្ឆិកា ឆ្នាំ២០២២ នាងខ្ញុំបានចេញពីស្រុកកំណើតខេត្តឧត្តរមានជ័យ មកភ្នំពេញ មកធ្វើការលក់ស៊ុប និងស្នាក់នៅជាមួយឈ្មោះ [redacted] ពៅ លុះដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ នាងខ្ញុំបានទៅជួយលក់កាហ្វេឱ្យអ៊ុំប្រុសម្នាក់ទៀតឈ្មោះ [redacted] តុលា និងស្នាក់នៅតូបលក់កាហ្វេនៅផ្ទះជួល ហើយនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ នាងខ្ញុំបានស្គាល់ឈ្មោះ [redacted] សុធាវិន ជាជាងម៉ូតូ នៅក្បែរតូបលក់កាហ្វេដែលខ្លួនលក់ ហើយក៏ទាក់ទងរាប់អានស្រឡាញ់គ្នាជាសង្សារ ។ បន្ទាប់មកនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ឈ្មោះ [redacted] សុធាវិន បានបើកម៉ូតូឌុបនាងខ្ញុំ ដើរលេងក្នុងរាជធានីភ្នំពេញ ដល់យប់បន្តិចឈ្មោះ [redacted] សុធាវិន បានបើកម៉ូតូឌុបនាងខ្ញុំមកលេងផ្ទះមិត្តភក្តិរបស់ឈ្មោះ [redacted] សុធាវិន ដោយយប់ជ្រៅឈ្មោះនេះ ក៏ឱ្យនាងខ្ញុំដេកនៅផ្ទះមិត្តភក្តិ ០១យប់ នាងខ្ញុំក៏យល់ព្រម ពេលនោះឈ្មោះ [redacted] សុធាវិន បានសុំនាងខ្ញុំដេកជាមួយគ្នា ដោយមានចិត្តស្រឡាញ់ នាងខ្ញុំក៏យល់ព្រម ហើយនាងខ្ញុំ និងឈ្មោះ [redacted] សុធាវិន បានដេករួមគ្នាសម្រេច ០១ដង នៅក្នុងបន្ទប់ផ្ទះមិត្តភក្តិ ហើយនៅយប់ក្នុងខែឧសភា ឆ្នាំ២០២៣ ឈ្មោះ [redacted] សុធាវិន ក៏សុំនាងខ្ញុំរួមភេទជាមួយម្តងទៀត នាងខ្ញុំប្រកែកឈ្មោះ [redacted] សុធាវិន បានសុំអង្វរនាងខ្ញុំជាច្រើនដង នាងខ្ញុំក៏ព្រមរួចនាងខ្ញុំ និងឈ្មោះ [redacted] សុធាវិន ក៏បានរួមភេទជាមួយគ្នា នៅក្នុងបន្ទប់ផ្ទះជួលលក់កាហ្វេសម្រេច មួយដងទៀត ។ បន្ទាប់ពី ០៣ថ្ងៃក្រោយឈ្មោះ [redacted] សុធាវិន ក៏បានមកលេងផ្ទះជួលលក់កាហ្វេនាងខ្ញុំ ក៏បាននិយាយគ្នាលេង ដល់យប់បន្តិចឈ្មោះ [redacted] សុធាវិន ក៏សុំនាងខ្ញុំរួមភេទជាមួយម្តងទៀត រួចនាងខ្ញុំ និងឈ្មោះ [redacted] សុធាវិន ក៏បានរួមភេទជាមួយគ្នាសម្រេចម្តងទៀត ។ លុះដល់ខែកក្កដា ឆ្នាំ២០២៣ នាងខ្ញុំក៏ចេញទៅរស់នៅជាមួយក្រុមគ្រួសារវិញ នៅខេត្តឧត្តរមានជ័យ បន្ទាប់មក/



Scanned with CamScanner

នៅយប់ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២៣ នាងខ្ញុំក៏និយាយសួរនាំ ជីដូនបង្កើតរបស់នាងខ្ញុំឈ្មោះ [redacted] សួត្រ ថា "យាយមនុស្សប្រុសស្រីដេកជាមួយគ្នាចំនួន ០៣ដង មានកូនអត់" ជីដូនតបថា "០១ដង ក៏មានដែរ" ពេលនោះនាងខ្ញុំក៏ប្រាប់រឿងហេតុឱ្យជីដូនបានដឹងថាធ្លាប់បានរួមភេទជាមួយសង្សារឈ្មោះ [redacted] សុធាវិន រួចជីដូនក៏ឱ្យនាងខ្ញុំឆាតទៅប្រាប់ឈ្មោះ [redacted] សុធាវិន ថាក្រុមគ្រួសារខ្ញុំដឹងរឿងអស់ហើយគិតម៉េចឡូវ ឈ្មោះ [redacted] សុធាវិន តបថានៅក្មេងចាំពីរ បីឆ្នាំទៀត ភ្លាមនោះជីដូនក៏នាំនាងខ្ញុំចេញពីខេត្តឧត្តរមានជ័យ មកដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលគោកឃ្លាង ហើយសមត្ថកិច្ចក៏បានចុះទៅឃាត់ឈ្មោះ [redacted] សុធាវិន យកមកសាកសួរ តែម្តង ។

-អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សួត្រ បានឆ្លើយថា៖ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២ មុនកើតហេតុដោយនៅក្នុងអំឡុងខែវិច្ឆិកា ឈ្មោះ [redacted] ម៉ារី បានធ្វើដំណើរចេញពីស្រុកកំណើតក្នុងគោលបំណងទៅភ្នំពេញ ហើយបានស្នាក់នៅផ្ទះឈ្មោះ [redacted] ពៅ ត្រូវជាក្មួយបង្កើតនាងខ្ញុំ ស្នាក់នៅភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។ លុះដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ឈ្មោះ [redacted] ម៉ារី បានធ្វើដំណើរត្រឡប់ពីភ្នំពេញមកស្រុកកំណើតវិញ ដើម្បីមកស្នាក់នៅជាមួយនាងខ្ញុំ ក្នុងអំឡុងពេលដែលឈ្មោះ [redacted] ម៉ារី ត្រឡប់មកស្នាក់នៅជាមួយនាងខ្ញុំវិញ បានសួរខ្ញុំដដែលៗ ច្រើនដងពេក លុះដល់ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២៣ នាងខ្ញុំក៏បានសួរនាំឈ្មោះ [redacted] ម៉ារី ថា "ម៉េចបានចេះតែសួររឿងអញ្ចឹងនិយាយមើល" ទើបឈ្មោះ [redacted] ម៉ារី បាននិយាយប្រាប់រឿងរ៉ាវរបស់ខ្លួន និងឈ្មោះ [redacted] សុធាវិន ឱ្យនាងខ្ញុំស្តាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] សុធាវិន បានឆ្លើយថា៖ ខ្ញុំពិតជាបានរួមភេទជាមួយឈ្មោះ ជា ម៉ារី ពិតមែន ដោយគ្មានការបង្ខំទេ ។ ខ្ញុំ និងឈ្មោះ [redacted] ម៉ារី ជាសង្សាជាមួយគ្នា ។ ជនរងគ្រោះ និងយាយរបស់គាត់នៅតែមានទំនាក់ទំនងជាមួយម្តាយខ្ញុំ ហើយគាត់បានដកពាក្យបណ្ដឹងវិញហើយ ដោយខ្ញុំចេញទៅវិញ និងផ្សំផ្គុំនឹងគ្នា ។ ខ្ញុំមិនបានដឹងថាឈ្មោះ [redacted] ម៉ារី អាយុប៉ុន្មានទេ ប៉ុន្តែគេជាប្អូនខ្ញុំ អាយុតិចជាងខ្ញុំ ។

-សាក្សីជាសមត្ថកិច្ចឈ្មោះ [redacted] សម្បត្តិ បានឆ្លើយថា៖ នៅក្នុងរឿងនេះ ជនជាប់ចោទបានសារភាពរួចហើយ ។

-សេចក្តីសន្និដ្ឋានមេធាវី [redacted] សឹងពន្លក តំណាងឱ្យជនរងគ្រោះ៖ ក្រោយការពិភាក្សាដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទបានសារភាពទោសកំហុស ដូចនេះស្នើសុំក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ៖ ដោយសារជនជាប់ចោទបានឆ្លើយសារភាព តំណាងអយ្យការយល់ឃើញថាចម្លើយសារភាពរបស់ជនចាប់ចោទមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងនៅក្នុងសំណុំរឿង ដូចនេះតំណាងអយ្យការសុំធ្វើការសន្និដ្ឋានដោយតម្កល់បទចោទ និងស្នើសុំក្រុមប្រឹក្សាពិចារណាផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានមេធាវី យាន សួគាណា ការពារសិទ្ធិឱ្យជនជាប់ចោទ៖ ក្រោយពីបានពិនិត្យសំណុំរឿង និងការពិភាក្សដេញដោលនាពេលសវនាការរួចឃើញ កូនក្តីខ្ញុំឈ្មោះ [redacted] សុធាវិន បានឆ្លើយសារភាពនៅគ្រប់នីតិវិធីទាំងអស់របស់តុលាការ និងនគរបាលយុត្តិធម៌ បានជាកូនក្តីខ្ញុំប្រព្រឹត្តអំពើបែបនេះ ដោយសារតែគាត់មិនបានយល់ដឹងអំពីបញ្ហាផ្លូវច្បាប់ ហើយពេលជាប់ពន្ធនាគារនេះ កូនក្តីខ្ញុំសន្យាថានឹងកែខ្លួនឱ្យក្លាយជាមនុស្សល្អសម្រាប់សង្គមជាតិ ក្រោយពេលចេញទៅវិញ ។ ដូចនេះ ក្នុងនាមខ្ញុំមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តល់ស្ថានសម្រាលទោសដល់កូនក្តីខ្ញុំតាមបញ្ញត្តិមាត្រា៩៣ និងមាត្រា៩៤ នៃក្រមព្រហ្មទណ្ឌ ។

-ជនជាប់ចោទឈ្មោះ [redacted] សុធាវិន បាននិយាយសម្តីចុងក្រោយថា៖ សុំតុលាការជួយបន្ធូរបន្ថយទោសឱ្យខ្ញុំបានឆាប់បានត្រលប់ទៅផ្ទះវិញ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី/



Scanned with CamScanner

-ក្រោយពីបានស្ដាប់ចម្លើយសារភាពរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់ចម្លើយសាក្សីជាសមត្ថកិច្ច

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនរងគ្រោះ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តុលាការបានទទួលជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៣៨០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៦២២៦ “ល” ដ.ជ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញដែលបានបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សុធាវិន ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ ពីបទរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីអំឡុងខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

២-តាមអំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ម៉ារី បានបញ្ជាក់ថា ខ្លួនបានស្គាល់ឈ្មោះ [redacted] សុធាវិន នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២៣ និងបានទាក់ទងគ្នាជាសង្សារ លុះដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣ ឈ្មោះ ខុន សុធាវិន បានជិះម៉ូតូមកឌុបខ្លួនទៅលេងផ្ទះមិត្តភក្ដិ ដោយយប់ជ្រៅពេក ឈ្មោះ [redacted] សុធាវិន បានឱ្យខ្លួនគេងនៅផ្ទះមិត្តភក្ដិតែម្ដង លុះពេលយប់ ឈ្មោះ [redacted] សុធាវិន បានសុំខ្លួនគេងជាមួយ ហើយបានសុំរួមភេទរហូតបានសម្រេចម្ដង ។ នៅយប់ក្នុងខែឧសភា ឆ្នាំ២០២៣ ដដែល ឈ្មោះ [redacted] សុធាវិន បានមកលេងខ្លួននៅផ្ទះលក់កាហ្វេ និងបាននិយាយគ្នាលេង លុះយប់បន្តិចឈ្មោះ [redacted] សុធាវិន បានសុំខ្លួនរួមភេទជាមួយ តែខ្លួនបានបដិសេធច្រើនដង តែឈ្មោះ [redacted] សុធាវិន នៅតែទទូចសុំរហូតរួមភេទបានសម្រេចម្ដងទៀត ។ បីថ្ងៃក្រោយមក ឈ្មោះ [redacted] សុធាវិន បានមកលេងខ្លួននៅផ្ទះលក់កាហ្វេ ហើយបានសុំខ្លួនរួមភេទជាមួយម្ដងទៀត ខ្លួនក៏យល់ព្រម រហូតរួមភេទបានសម្រេច ។

៣-យោងតាមចម្លើយជនរងគ្រោះឈ្មោះ [redacted] ម៉ារី បានឆ្លើយនៅដំណាក់កាលសមត្ថកិច្ច និងដំណាក់កាលអយ្យការ មានភាពស៊ីសង្វាក់ជាមួយចម្លើយជនជាប់ចោទ និងចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ដែលអាចបញ្ជាក់បានថាពិតជាមានអង្គហេតុដែលជនជាប់ចោទឈ្មោះ [redacted] សុធាវិន បានរួមភេទជាមួយខ្លួន ពិតប្រាកដមែន ។

៤-ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថា នៅអំឡុងខែឧសភា ឆ្នាំ២០២៣ ជនជាប់ចោទឈ្មោះ [redacted] សុធាវិន បានធ្វើសកម្មភាពរួមភេទជាមួយជនរងគ្រោះជាអនីតិជនអាយុក្រោម១៥ឆ្នាំ ឈ្មោះ [redacted] ម៉ារី ប្រាកដមែន ។

៥-តាមរបាយការណ៍សំយោគលេខ ១៨០/២៣ របក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៣ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខ នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថាឈ្មោះ [redacted] សុធាវិន ពិតជាបានរួមភេទជាមួយអនីតិជនអាយុ ១២ឆ្នាំ បានសម្រេចចំនួន ០៣ដង ប្រាកដមែន ។

៦-តាមចម្លើយរបស់ជនរងគ្រោះ ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងចម្លើយជនជាប់ចោទ ព្រមទាំងភស្តុតាងផ្សេងៗ ដែលមាននៅក្នុងសំណុំរឿងមានលក្ខណៈស៊ីសង្វាក់បញ្ជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស



Scanned with CamScanner

អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីអំឡុងខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៧-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] សុធាវិន ដែលបានធ្វើសកម្មភាពរួមភេទជាមួយជនរងគ្រោះជាអនីតិជន អាយុក្រោម១៥ឆ្នាំ ត្រូវបានច្បាប់កំណត់ជាបទល្មើស ហើយបញ្ញត្តិឲ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំទៅ ១០ (ដប់) ឆ្នាំ តាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ[redacted] សុធាវិន ធ្វើឲ្យប៉ះពាល់ដល់រូបរាងកាយ ផ្លូវភេទ សេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះ កិត្តិយសរបស់ជនរងគ្រោះ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម ដែលកំណត់ជាបទល្មើសតាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៩-ជនជាប់ចោទឈ្មោះ [redacted] សុធាវិន ជាអនីតិជន និងជាជនដែលមានទីតិសម្បទាស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។ តុលាការនឹងប្រកាសទោសលើជនជាប់ចោទឈ្មោះ ខុន សុធាវិន តាមបញ្ញត្តិមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ ដោយសារជនជាប់ចោទជាអនីតិជនអាយុលើស ១៤ឆ្នាំ ។

១០-ការលើកឡើងរបស់មេធាវីការពារសិទ្ធិឲ្យជនរងគ្រោះក្នុងសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានសារភាព ហើយស្នើសុំក្រុមប្រឹក្សាជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ តុលាការនឹងពិចារណាតាមអង្គហេតុដែលបានកើតឡើង ។

១១-ការលើកឡើងរបស់តំណាងអយ្យការក្នុងសេចក្តីសន្និដ្ឋាននាពេលសវនាការដោយលើកឡើងពីពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុធាវិន មានភាពត្រឹមត្រូវតាមច្បាប់ ។

១២-មេធាវីការពារសិទ្ធិជនជាប់ចោទបានសន្និដ្ឋានការពារថា កូនក្តីខ្លួនបានសារភាពទោសកំហុស និងសន្យាកែប្រែខ្លួនក្រោយចេញពីពន្ធនាគារវិញ ដោយសំណូមពរតុលាការបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។ តុលាការយល់ឃើញថាមានភាពត្រឹមត្រូវតាមអង្គហេតុដែលបានកើតឡើង ។ ចំណែកការស្នើសុំស្តានសម្រាលទោសដល់ជនជាប់ចោទ តុលាការនឹងពិនិត្យពិចារណាលើកាលៈទេសៈនៃបទល្មើសដែលបានប្រព្រឹត្ត និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទជាអនីតិជនមានការសោកស្តាយក្រោយពេលប្រព្រឹត្តបទល្មើស ។

១៣-មានភស្តុតាងបញ្ជាក់ពីពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សុធាវិន ពីបទ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីអំឡុងខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

១៤-តុលាការនឹងប្រកាសទោសដាក់ពន្ធនាគារអប្បបរមា នៃទោសចំពោះជនជាប់ចោទឈ្មោះ [redacted] សុធាវិន តុលាការពិចារណាក្នុងការប្រកាសឲ្យព្យួរការអនុវត្តទោសមួយផ្នែក ដើម្បីទុកឱកាសឲ្យជនជាប់ចោទបានកែប្រែខ្លួនដោយជនជាប់ចោទជានិងអនីតិជន ហើយជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសដែលត្រូវតុលាការផ្តន្ទាទោសជាលើកទី១ ហើយទោសដែលនឹងប្រកាសមានរយៈពេលមិនលើសពី ០៥ (ប្រាំ) ឆ្នាំ យោងតាមមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ ។

១៥-នាពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្មូត្រ អវត្តមាន ហើយនៅដំណាក់កាលចៅក្រមស៊ើបសួរដើមបណ្តឹងរដ្ឋប្បវេណីបានសុំដកពាក្យបណ្តឹង ដូចមានពាក្យសុំដកពាក្យបណ្តឹងចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ ដូច្នេះតុលាការពុំពិចារណាសម្រេចអំពីសំណងរដ្ឋប្បវេណីទេ ។



Scanned with CamScanner

## ហេតុដូច្នេះសម្រេច

-ផ្តន្ទាទោសឈ្មោះ [redacted] សុធាវិន ភេទប្រុស អាយុ ១៦ឆ្នាំ ជនជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ២(ពីរ) ឆ្នាំ ៦(ប្រាំមួយ) ខែ អនុវត្តទោសពន្ធនាគារ ១(មួយ) ឆ្នាំ ទោសពន្ធនាគារដែលនៅសល់ត្រូវព្យួរតាមបញ្ញត្តិមាត្រា ១០៤-១០៨ នៃក្រមព្រហ្មទណ្ឌ ពីបទ **រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចផ្ទះជួល ផ្លូវបេតុង ភូមិគោកឃ្លាង សង្កាត់គោកឃ្លាង ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីអំឡុងខែឧសភា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ចំពោះមុខជនជាប់ចោទ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៤កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner